ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០០៥ រដនស/សណន

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តគ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ និងលិខិតអនុញ្ញាតសាងសង់ ស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ផ្អែកតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលិខិតអនុញ្ញាតសាងសង់ និងដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងការងារនគរូបនីយកម្មនិងសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងសាធារណជនទូទៅ ដូចខាងក្រោម÷

### ក. គ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់

១. ចំពោះទីតាំងដែលមានប្លង់គ្លាតម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់គ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមប្លង់តម្រង់ជួរដែលមានស្រាប់ស្របច្បាប់ ឬតាមផែនការប្រើប្រាស់ដីដែលបានធ្វើការព្យាករណ៍សម្រាប់លទ្ធភាពពង្រីកផ្លូវ នាពេលអនាគត។

២. ចំពោះទីតាំងដែលពុំមានប្លង់គ្លាតម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់គ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមបទដ្ឋានដូចខាងក្រោម÷

#### ២.១. អគារកម្ពស់ទាប÷ ជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២

- គ្លាតម្លាតខាងមុខ ឬគម្លាតជាប់ផ្លូវ ប្រវែងយ៉ាងតិច ៤ (បួន) ម៉ែត្រ គម្លាតនេះអាចកំណត់យ៉ាងតិចប្រវែង ២ (ពីរ) ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចង្អៀត និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ។
- គ្លាតម្លាតខាងក្រោយ និងចំហៀងសងខាងត្រូវរក្សាទុកយ៉ាងតិច ប្រវែង ២ (ពីរ) ម៉ែត្រ។
- ក្នុងករណីទំហំក្បាលដីឡូតិ៍មានប្រវែងតូចជាង ២០ម៉ែត្រ គ្លាតម្លាតចំហៀងសងខាងត្រូវរក្សាទុកយ៉ាងតិច ១០% នៃប្រវែងក្បាលដី។


អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- ក្នុងករណីទំហំក្បាលដីឡូតិ៍មានប្រវែងតូចជាង ១០ម៉ែត្រ ធ្លាតម្លាតចំហៀងសងខាងត្រូវរក្សាទុកយ៉ាងតិចប្រវែង ១(មួយ) ម៉ែត្រ ឬអាចជាប់ព្រំ ឬជញ្ជាំងអឡូសិទ្ធិ។
- ចំពោះសំណង់ដែលស្ថិតនៅក្នុងតំបន់លំនៅឋានជាប់ ត្រូវរក្សាតម្លាតអប្បបរមានៅជាប់ផ្លូវ ប្រវែង ៤(បួន) ម៉ែត្រ ឬរក្សាតាមជួរតម្រង់ កម្ពស់ និងរចនាបទអគារជិតខាងដែលមានស្រាប់ស្របច្បាប់ ហើយចំហៀងសងខាងអាចសាងសង់ជាប់ព្រំ ឬជញ្ជាំងអឡូសិទ្ធិ។
- ម្ចាស់សំណង់ត្រូវទទួលខុសត្រូវរាល់ផលប៉ះពាល់អគារអ្នកជិតខាង ដែលបណ្ដាលមកពីការសាងសង់អគាររបស់ខ្លួន ដោយត្រូវជួសជុល ឬសាងសង់ឡើងវិញទៅតាមទំហំនៃការខូចខាតជាក់ស្ដែង។

**២.២. អគារកម្ពស់មធ្យម៖ ជាន់ទី៣ ដល់ជាន់ទី១១**

**២.២.១. អគារមានកម្ពស់ចាប់ពីជាន់ទី៣ ដល់ជាន់ទី៨**

- ធ្លាតម្លាតខាងមុខ ឬតម្លាតជាប់ផ្លូវ ត្រូវរក្សាទុកប្រវែងយ៉ាងតិច ៤(បួន) ម៉ែត្រ។ តម្លាតនេះអាចកំណត់យ៉ាងតិចប្រវែង ២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់ក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ។
- ធ្លាតម្លាតខាងក្រោយនិងចំហៀងសងខាង ប្រវែងយ៉ាងតិច ២(ពីរ)ម៉ែត្រ។
- ក្នុងករណីទំហំក្បាលដីឡូតិ៍មានប្រវែងតូចជាង ២០ម៉ែត្រ ធ្លាតម្លាតចំហៀងសងខាងត្រូវរក្សាទុកយ៉ាងតិច ១០% នៃប្រវែងក្បាលដី។
- ក្នុងករណីទំហំក្បាលដីឡូតិ៍តូចជាង ១០ម៉ែត្រ ធ្លាតម្លាតចំហៀងសងខាងត្រូវរក្សាទុកប្រវែងយ៉ាងតិច ១ (មួយ) ម៉ែត្រ ឬ អាចជាប់ព្រំ ឬ ជញ្ជាំងអឡូសិទ្ធិ។
- ចំពោះសំណង់ដែលស្ថិតនៅក្នុងតំបន់លំនៅឋានជាប់ ត្រូវរក្សាតម្លាតអប្បបរមាជាប់ផ្លូវប្រវែង ៤(បួន) ម៉ែត្រ ឬរក្សាតាមជួរតម្រង់ កម្ពស់ និងរចនាបទអគារជិតខាងមានស្រាប់ស្របច្បាប់ ហើយចំហៀងសងខាងអាចសាងសង់ជាប់ព្រំ ឬជញ្ជាំងអឡូសិទ្ធិ។
- ម្ចាស់សំណង់ត្រូវទទួលខុសត្រូវរាល់ផលប៉ះពាល់អគារអ្នកជិតខាង ដែលបណ្ដាលមកពីការសាងសង់អគាររបស់ខ្លួន ដោយត្រូវជួសជុល ឬសាងសង់ឡើងវិញទៅតាមទំហំនៃការខូចខាតជាក់ស្ដែង។

**២.២.២. អគារមានកម្ពស់ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១**

- ត្រូវបន្តអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ៤២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**ខ. អំពីការផ្ដល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**១. ការផ្ដល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

- ចំពោះសំណង់ស្ថិតក្នុងសមត្ថកិច្ចរដ្ឋបាលរាជធានីខេត្ត លើទីតាំងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុច ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅអង្គភាពច្រកចេញចូលតែមួយ

នៃរដ្ឋបាលរាជធានី ខេត្ត។ អង្គភាពច្រកចេញចូលតែមួយ ត្រូវបញ្ជូនសំណុំឯកសារមកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ដើម្បីបំពេញបែបបទតាមនីតិវិធី ធ្វើសលាកបត្រក្បាលដី សិក្សាគួរប្លង់ស្ថាបត្យកម្ម និងរៀបចំរបាយការណ៍បច្ចេកទេសដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច។

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ ២៥ (ម្ភៃប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។
- ទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតសាងសង់ស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត មានជូនភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីណែនាំនេះ។

**២. ការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

- ចំពោះសំណង់ស្ថិតក្នុងសមត្ថកិច្ចរដ្ឋបាលក្រុង ស្រុក ខណ្ឌ លើទីតាំងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការិយាល័យច្រកចេញចូលតែមួយ ត្រូវបញ្ជូនសំណុំឯកសារមកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបំពេញបែបបទតាមនីតិវិធី ធ្វើសលាកបត្រក្បាលដី សិក្សាគួរប្លង់ស្ថាបត្យកម្ម និងរៀបចំរបាយការណ៍បច្ចេកទេសដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ និងសម្រេច។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុងស្រុកខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។
- ទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតសាងសង់ស្ថិតនៅក្រោមសមត្ថកិច្ចរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានជូនភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ២ នៃសេចក្តីណែនាំនេះ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វិញ។

ថ្ងៃចន្ទ ៦រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង
- គ្រប់នាយកដ្ឋានជំនាញពាក់ព័ន្ធ ក្រោមឱវាទក្រសួង
- រដ្ឋបាលរាជធានី-ខេត្ត
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ